# លក្ខខណ្ឌនៃគុណតម្លៃរបស់ប័ណ្ណ

## ១. កម្មវិធីការចំណាយ និង សន្សំពិន្ទុ

### ១.១ លក្ខខណ្ឌដើម្បីទទួលបាន

- ការផ្តល់ជូននេះ គឺសម្រាប់តែម្ចាស់ប័ណ្ណឥណទាន **ប្រ៊ីដ វីសា រីសឺវ** តែប៉ុណ្ណោះ (រួមទាំងប័ណ្ណបង្គោល និង ប័ណ្ណរង) ។

### ១.២ ពិន្ទុ Shangri-La Circle (SLC)

- រាល់ប្រតិបត្តិការទិញទំនិញដែលជោគជ័យ ចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០២៥ តទៅ ដែលមានតម្លៃចាប់ពី ៥០ដុល្លារអាមេរិក សម្រាប់ប័ណ្ណបង្គោល និង ប័ណ្ណរង នឹងទទួលបាន ១ ពិន្ទុ SLC។ ចំនួនទឹកប្រាក់ដុល្លារអាមេរិកនឹងត្រូវបានគិតជាប្រាក់រៀល (KHR) ដោយផ្អែកលើអត្រាប្តូរប្រាក់ថេរ ១ ដុល្លារអាមេរិក = ៤,000.00 រៀល។
- ការទទួលបានពិន្ទុ SLC គឺគ្មានដែនកំណត់ទេ។
- ពិន្ទុ SLC នឹងត្រូវបានបញ្ចូលទៅក្នុងគណនីសមាជិក Shangri-La Circle របស់ម្ចាស់ប័ណ្ណ មុនថ្ងៃទី ១៥ នៃខែបន្ទាប់ បន្ទាប់ពីប្រតិបត្តិការបានបញ្ចប់ប្រកបដោយជោគជ័យ និងការផ្ទៀងផ្ទាត់លក្ខខណ្ឌគ្រប់គ្រាន់។

### ១.៣ ប្រតិបត្តិការមានការបង្វិលត្រឡប់មកវិញ

- ក្នុងករណីមានប្រតិបត្តិការបង្វិលត្រឡប់មកវិញ ដែលម្ចាស់ប័ណ្ណបានចំណាយទឹកប្រាក់មានសិទ្ធិក្នុងការទទួលបានពិន្ទុ SLC ប៉ុន្តែទឹកប្រាក់នោះត្រូវបានបង្វិលត្រឡប់មកឲ្យម្ចាស់ប័ណ្ណវិញដោយហាង រួមទាំងប្រតិបត្តិការបង្វិលសងលើពន្ធ ធនាគារ ប្រ៊ីដ រក្សាសិទ្ធិក្នុងការលុបចោល/កាត់បន្ថយពិន្ទុ SLC ហើយនឹងត្រូវបានកែតម្រូវក្នុងពិន្ទុដែលគ្រោងនឹងបញ្ចូលក្នុងគណនីនាខែបន្ទាប់។

### ១.៤ លក្ខខណ្ឌនៃការប្រើប្រាស់

- ក្នុងករណីដែលម្ចាស់ប័ណ្ណដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍ពុំបានផ្តល់លេខសមាជិក Shangri-La Circle មកធនាគារ ប្រ៊ីដ ម្ចាស់ប័ណ្ណនឹងមិនអាចទទួលបានអត្ថប្រយោជន៍ពីកម្មវិធី ឬអត្ថប្រយោជន៍ពីការផ្តល់ជូននេះឡើយ។ ធនាគារ ប្រ៊ីដ នឹងផ្តល់ពិន្ទុ SLC ដល់ម្ចាស់ប័ណ្ណសម្រាប់តែប្រតិបត្តិការដែលបានគណនា បន្ទាប់ពីទទួលបានលេខសមាជិក Shangri-La Circle តែប៉ុណ្ណោះ។

- អត្ថប្រយោជន៍ដែលទទួលបានពីកម្មវិធីនេះមិនអាចផ្ទេរ ឬកបញ្ចូលគ្នា ប្តូរជាសាច់ប្រាក់ ឬផលិតផលផ្សេងទៀតបានទេ ហើយមិនអាចប្រើប្រាស់រួមជាមួយការផ្តល់ជូនផ្សេង ឬ បញ្ចុះតម្លៃលើទំនិញផ្សេងទៀតបានឡើយ លើកលែងតែអត្ថប្រយោជន៍ដែលផ្តល់ជូនដោយផ្ទាល់ពីកម្មវិធី Shangri-La Circle។
- លក្ខខណ្ឌរបស់ Shangri-La Circle ត្រូវបានអនុវត្ត។

### ១.៥ សម្រាប់សេវាប្រឹក្សាយោបល់អតិថិជន

- ប្រសិនបើ ម្ចាស់ប័ណ្ណមានចម្ងល់ទាក់ទងនឹងសមាជិក Shangri-La Circle សូមធ្វើការទាក់ទងទៅកាន់សេវាកម្មសមាជិក Shangri-La Circle ដោយផ្ទាល់តាមរយៈ shangri-la.circle@shangri-la.com។
- ប្រសិនបើលោកអ្នកត្រូវការព័ត៌មានបន្ថែម ត្រូវការជំនួយ ឬជួបប្រទះបញ្ហាណាមួយ សូមទាក់ទងមកកាន់យើងខ្ញុំតាមរយៈ

**លេខទូរសព្ទ**: ១៨០០ ២០២ ៩៩៩/ ០៩៨ ២០២ ៩៩៩
**អ៊ីម៉ែល**: info@bridgebank.com.kh
**ហ្វេសប៊ុក**: BRIDGE Bank

### ១.៦ វិសោធនកម្ម និង ការបកស្រាយ

- ធនាគារ ប្រ៊ីជ រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរលក្ខខណ្ឌនានាគ្រប់ពេលវេលា រួមទាំង ការកំណត់ផ្លាស់ប្តូរប្រភេទប័ណ្ណដែលនឹងត្រូវផ្តល់ជូន និង យន្តការគណនា ឬធ្វើការបញ្ចប់ការផ្តល់ជូននេះដោយគ្មានការជូនដំណឹងជាមុនដល់ម្ចាស់ប័ណ្ណ។
- រាល់ការបកស្រាយលើលក្ខខណ្ឌទាំងនេះ គឺជាឆន្ទានុសិទ្ធិផ្តាច់មុខរបស់ធនាគារ **ប្រ៊ីជ** និង Shangri-La Circle។ ក្នុងករណីមានវិវាទលើការបកស្រាយនៃលក្ខខណ្ឌនេះ ការសម្រេចរបស់ធនាគារ ប្រ៊ីជ និង Shangri-La Circle គឺត្រូវចាត់ទុកជាការសម្រេចចុងក្រោយ។

BRIDGE BANK

## ២. កម្មវិធីសមាជិក Shangri-La Circle

### ២.១ លក្ខខណ្ឌដើម្បីទទួលបាន

- កម្មវិធីនេះគឺសម្រាប់តែម្ចាស់ប័ណ្ណឥណទាន **ប្រ៊ីដ វីសា រីសឺវ** (ទាំងប័ណ្ណបង្គោល និង ប័ណ្ណរង) ត្រូវបានអនុវត្តចំពោះរាល់ការទិញទំនិញ ដែលប្រើប្រាស់ប័ណ្ណឥណទាន **ប្រ៊ីដ វីសា រីសឺវ**។

### ២.២ សមាជិក Shangri-La Circle

- សម្រាប់ម្ចាស់ប័ណ្ណឥណទាន **ប្រ៊ីដ វីសា រីសឺវ** (ទាំងប័ណ្ណបង្គោល និង ប័ណ្ណរង) នឹងត្រូវបានផ្តល់ជាសមាជិក Shangri-La Circle ស្របតាមការចំណាយសរុបប្រចាំឆ្នាំដែលមានលក្ខខណ្ឌដូចខាងក្រោម៖

| **ការចំណាយសរុបប្រចាំឆ្នាំ** | **ការផ្តល់ជូន** |
|---|---|
| ១,000,000 ទៅ ១,៤៩៩,៩៩៩ ដុល្លារអាមេរិក | សមាជិកភាព Shangri-La Circle Jade បូកជាមួយពិន្ទុ SLC ១0,000 ពិន្ទុ |
| ១,៥00,000ដុល្លារអាមេរិកឡើងទៅ | សមាជិកភាព Shangri-La Circle Diamond បូកជាមួយពិន្ទុ SLC ៥0,000 ពិន្ទុ |

- ការចំណាយត្រូវគណនាជាប្រាក់ដុល្លារអាមេរិក (ដែលនឹងត្រូវបានអត្រាប្តូរជាប្រាក់រៀល (KHR) តាមអត្រាថេរ ១ ដុល្លារ = ៤,000.00 រៀល)។ រាល់ការចំណាយទាំងអស់នឹងត្រូវគិតពេញមួយឆ្នាំ ចាប់ពីថ្ងៃទី0១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែធ្នូ ដោយមិនមានគិតបញ្ចូលពីកាលបរិច្ឆេទចេញប័ណ្ណឡើយ។
- ចំនួនទឹកប្រាក់ដែលបានចំណាយនៃឆ្នាំចាស់ នឹងមិនត្រូវបានរួមបញ្ចូលជាមួយចំនួនទឹកប្រាក់ដែលបានចំណាយក្នុងឆ្នាំបន្ទាប់បានឡើយ។
- ចំពោះម្ចាស់ប័ណ្ណដែលទទួលបានសមាជិកភាព Jade ឬ Diamond ពី Shangri-La Circle ធនាគារប្រ៊ីដនឹងធ្វើការបញ្ចូលសមាជិកភាពនៅក្នុងគណនីសមាជិកភាព មុនថ្ងៃទី ១៥ នៃខែបន្ទាប់ នៅពេលដែលម្ចាស់ប័ណ្ណបានបំពេញតាមគ្រប់លក្ខខណ្ឌរបស់កម្មវិធីនេះ ។
- ពិន្ទុ SLC នឹងត្រូវបានបញ្ចូលទៅក្នុងគណនីសមាជិកភាព Shangri-La Circle របស់ម្ចាស់ប័ណ្ណ មុនថ្ងៃទី ១៥ នៃខែបន្ទាប់ នៅពេលដែលម្ចាស់ប័ណ្ណបំពេញតាមលក្ខខណ្ឌរបស់កម្មវិធីនេះ។

## ២.៣ លក្ខខណ្ឌនៃការប្រើប្រាស់

- ការផ្តល់សមាជិកភាព Shangri-La Circle ដែលត្រូវបានផ្តល់ជូននេះ មានសុពលភាពរហូតដល់ថ្ងៃទី៣១ ខែធ្នូ ២០២៦។
- សម្រាប់សមាជិករបស់កម្មវិធី Shangri-La Circle ដែលកំពុងស្ថិតក្នុងប្រភេទ Jade ឬ Diamondរួចហើយ ដែលសមាជិកភាពផុតកំណត់នៅថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំបច្ចុប្បន្ន ហើយម្ចាស់ប័ណ្ណបានបំពេញតាមលក្ខខណ្ឌកម្មវិធីរបស់ធនាគារ ប្រ៊ីដ នឹងទទួលបានការបន្តសុពលភាពសមាជិកភាពរហូតដល់ថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំបន្ទាប់។
- លក្ខខណ្ឌសម្រាប់ការបន្តសុពលភាពបន្ទាប់ពីរយៈពេលសុពលភាពដែលបានរៀបរាប់ខាងលើ គឺស្ថិតក្រោមលក្ខខណ្ឌរបស់ Shangri-La Circle។
- ក្នុងករណីម្ចាស់ប័ណ្ណដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍ ប៉ុន្តែពុំបានផ្តល់លេខសមាជិកភាព Shangri-La Circle មកធនាគារ ប្រ៊ីដ ម្ចាស់ប័ណ្ណនឹងមិនអាចទទួលបានអត្ថប្រយោជន៍ពីកម្មវិធីនេះឡើយ។ ធនាគារ ប្រ៊ីដ នឹងផ្តល់ពិន្ទុ SLC ដល់ម្ចាស់ប័ណ្ណសម្រាប់តែប្រតិបត្តិការទាំងឡាយណាដែលបានទូទាត់ គិតចាប់ពីថ្ងៃដែលធនាគារទទួលបានលេខសមាជិក Shangri-La Circle តែប៉ុណ្ណោះ។
- ការផ្តល់ជូននេះមិនអាចផ្ទេរ ប្តូរបញ្ចូលគ្នាប្តូរជាសាច់ប្រាក់ ឬផលិតផលផ្សេងទៀតបានទេ ព្រមទាំងមិនអាចប្រើប្រាស់រួមជាមួយការផ្តល់ជូនផ្សេងៗទៀត ឬ ទំនិញបញ្ចុះតម្លៃបានឡើយ លើកលែងតែអត្ថប្រយោជន៍ដែលផ្តល់ជូនដោយផ្ទាល់ពី Shangri-La Circle។
- លក្ខខណ្ឌរបស់ Shangri-La Circle ត្រូវបានអនុវត្ត។

## ២.៤ សម្រាប់សេវាប្រឹក្សាយោបល់អតិថិជន

- ប្រសិនបើលោកអ្នកត្រូវការព័ត៌មានបន្ថែម ត្រូវការជំនួយ ឬជួបប្រទះបញ្ហាណាមួយ សូមទាក់ទងមកកាន់យើងខ្ញុំតាមរយៈ

**លេខទូរសព្ទ:** ១៨០០ ២០២ ៩៩៩/ ០៩៨ ២០២ ៩៩៩
**អ៊ីម៉ែល:** info@bridgebank.com.kh
**ហ្វេសប៊ុក:** BRIDGE Bank

## ២.៥ វិសោធនកម្ម និង ការបកស្រាយ

BRIDGE BANK

- ធនាគារ ប្រ៊ីដ រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរលក្ខខណ្ឌនានាគ្រប់ពេលវេលា រួមទាំង ការកំណត់ផ្លាស់ប្តូរប្រភេទប័ណ្ណដែលនឹងត្រូវផ្តល់ជូន និង យន្តការគណនា ឬការបញ្ចប់ការផ្តល់ជូននេះដោយគ្មានការជូនដំណឹងជាមុនដល់ម្ចាស់ប័ណ្ណឡើយ។
- រាល់ការបកស្រាយលើលក្ខខណ្ឌទាំងនេះ គឺជាឆន្ទានុសិទ្ធិផ្តាច់មុខរបស់ធនាគារ **ប្រ៊ីដ** និង Shangri-La Circle។ រាល់វិវាទលើលក្ខខណ្ឌនេះ ការសម្រេចរបស់ធនាគារ **ប្រ៊ីដ** និង Shangri-La Circle គឺចាត់ទុកជាការសម្រេចចុងក្រោយ។

## ៣. ការតម្លើងសមាជិកភាពពិសេសទៅជា Shangri-La Circle ប្រភេទ Jade

### ៣.១ លក្ខខណ្ឌដើម្បីទទួលបាន

- កម្មវិធីនេះគឺសម្រាប់តែម្ចាស់ប័ណ្ណឥណទាន **ប្រ៊ីដ វីសា រីស៊ីវ** (ទាំងប័ណ្ណបង្គោល និង ប័ណ្ណរង)**៣.២ សមាជិកភាព Shangri-La Circle**
- ដើម្បីក្លាយជាសមាជិកភាព Shangri-La Circle ប្រភេទ Jade ម្ចាស់ប័ណ្ណបង្គោល និង ប័ណ្ណរងត្រូវស្នាក់នៅយ៉ាងតិចចំនួន១០ យប់ឡើងទៅ ហើយបានធ្វើការទូទាត់ដោយប័ណ្ណឥណទាន **ប្រ៊ីដ វីសា រីស៊ីវ** នៅសណ្ឋាគារ Shangri-La, Kerry, JEN, Traders ណាមួយក្នុងមួយឆ្នាំ ។
- សម្រាប់ការតម្លើងទៅជាសមាជិកភាព Shangri-La Circle ប្រភេទ Jade នេះ តម្រូវអោយមានការស្នាក់នៅបង់ប្រាក់តាមអត្រាតម្លៃបន្ទប់ប៉ុណ្ណោះ ដែលត្រូវបានរាប់បញ្ចូល ដោយមិនរាប់បញ្ចូលការស្នាក់នៅរយៈពេលវែងនិងការប្តូរយករង្វាន់ជាបន្ទប់ឡើយ។
- ដើម្បីទទួលបានការផ្តល់ជូននេះ ម្ចាស់ប័ណ្ណត្រូវតែទូទាត់វិក្កយបត្រ នៅពេលចាកចេញពីសណ្ឋាគារ ដោយប្រើប្រាស់ប័ណ្ណ **ប្រ៊ីដ វីសា រីស៊ីវ** របស់ខ្លួន។

### ៣.៣ លក្ខខណ្ឌនៃការប្រើប្រាស់

- ដើម្បីទទួលបានអត្ថប្រយោជន៍នេះ ម្ចាស់ប័ណ្ណត្រូវតែផ្តល់លេខសមាជិក Shangri-La Circle របស់ខ្លួនទៅធនាគារ ប្រ៊ីដ សម្រាប់ការចុះឈ្មោះ មុនថ្ងៃចូលស្នាក់នៅ។ តាមរយៈការចុះឈ្មោះសម្រាប់អត្ថប្រយោជន៍នេះ ម្ចាស់ប័ណ្ណយល់ព្រមទទួលយកលក្ខខណ្ឌទាំងអស់ដូចដែលបានចែងក្នុងប្រការ ៣។

- ក្នុងករណីដែលម្ចាស់ប័ណ្ណដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍ពុំបានផ្តល់លេខសមាជិក Shangri-La Circle មកធនាគារ ប្រ៊ីជ ម្ចាស់ប័ណ្ណនឹងមិនអាចទទួលបានអត្ថប្រយោជន៍ពីការផ្តល់ជូនរបស់កម្មវិធីនេះឡើយ។
- សម្រាប់ម្ចាស់ប័ណ្ណដែលចុះឈ្មោះលើកម្មវិធីដែលបានផ្តល់ជូននេះមុនបំណាច់ខែ ការចុះឈ្មោះនឹងមានប្រសិទ្ធភាពនៅថ្ងៃទី ១៥ នៃខែបន្ទាប់ ហើយម្ចាស់ប័ណ្ណមានសិទ្ធិអាចចាប់ផ្តើមរាប់បញ្ចូលក្នុងកម្មវិធីស្នាក់នៅដែលចាប់ពីថ្ងៃនោះតទៅ។
- ការតម្លើងសមាជិកភាពនឹងត្រូវធ្វើឡើងមុនថ្ងៃទី ១៥ នៃខែបន្ទាប់ ក្រោយពេលដែលអតិថិជនបានបំពេញគ្រប់លក្ខខណ្ឌរបស់កម្មវិធី។
- ការតម្លើងសមាជិកភាព Shangri-La Circle ប្រភេទ Jade ត្រូវបានផ្តល់ជូនសម្រាប់សមាជិកភាពដែលមានសពុលភាពក្នុងឆ្នាំបច្ចុប្បន្នប៉ុណ្ណោះ។ ចំពោះការបន្តសមាជិកភាពនៅឆ្នាំបន្ទាប់ ត្រូវបានអនុវត្តតាមលក្ខខណ្ឌរបស់ Shangri-La Circle។
- ការផ្តល់ជូននេះមិនត្រូវបានអនុវត្តសម្រាប់ការបន្តសមាជិកភាព Shangri-La Circle Jade ទេ។
- ការផ្តល់ជូននេះមិនអាចផ្ទេរបាន ឬ បូកបញ្ចូលគ្នាបាន ឬ ប្តូរជាសាច់ប្រាក់ ឬ ផលិតផលផ្សេងទៀតបានទេ ហើយមិនអាចប្រើប្រាស់រួមជាមួយការផ្តល់ជូនផ្សេង ឬ បញ្ចុះតម្លៃលើទំនិញផ្សេងទៀតបានឡើយ លើកលែងតែអត្ថប្រយោជន៍ណាមួយដែលផ្តល់ជូនដោយផ្ទាល់ពី Shangri-La Circle។
- លក្ខខណ្ឌរបស់ Shangri-La Circle ត្រូវបានអនុវត្ត។

### ៣.៤ សម្រាប់សេវាប្រឹក្សាយោបល់អតិថិជន

ប្រសិនបើមានចម្ងល់ទាក់ទងនឹងសមាជិកភាព Shangri-La Circle ម្ចាស់ប័ណ្ណ សូមទំនាក់ទំនងទៅកាន់សេវាកម្មសមាជិក Shangri-La Circle ដោយផ្ទាល់តាមរយៈ shangri-la.circle@shangri-la.com។

- ប្រសិនបើលោកអ្នកត្រូវការព័ត៌មានបន្ថែម ត្រូវការជំនួយ ឬជួបប្រទះបញ្ហាណាមួយ សូមទាក់ទងមកកាន់យើងខ្ញុំតាមរយៈ

**លេខទូរសព្ទ:** ១៨០០ ២០២ ៩៩៩/ ០៩៨ ២០២ ៩៩៩
**អ៊ីម៉ែល:** info@bridgebank.com.kh
**ហ្វេសប៊ុក:** BRIDGE Bank

### ៣.៥ វិសោធនកម្ម និង ការអធិប្បាយ

- ធនាគារ ប្រ៊ីជ រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរលក្ខខណ្ឌនានាគ្រប់ពេលវេលា រួមទាំង ការកំណត់ផ្លាស់ប្តូរប្រភេទប័ណ្ណដែលនឹងត្រូវផ្តល់ជូន និង រូបមន្តគណនា ឬការបញ្ចប់ការផ្តល់ជូននេះដោយគ្មានការជូនដំណឹងជាមុនដល់ម្ចាស់ប័ណ្ណឡើយ។
- រាល់ការបកស្រាយលើលក្ខខណ្ឌទាំងនេះ គឺជាឆន្ទានុសិទ្ធិផ្តាច់មុខរបស់ធនាគារ **ប្រ៊ីជ** និង Shangri-La Circle។ រាល់វិវាទលើលក្ខខណ្ឌនេះ ការសម្រេចរបស់ធនាគារ **ប្រ៊ីជ** និង Shangri-La Circle គឺចាត់ទុកជាការសម្រេចចុងក្រោយ។

## ៤. សាលរង់ចាំពិសេសនៅតាមអាកាសយានដ្ឋាន

### ៤.១លក្ខខណ្ឌដើម្បីទទួលបាន

- កម្មវិធីនេះគឺសម្រាប់តែម្ចាស់ប័ណ្ណដូចខាងក្រោមប៉ុណ្ណោះ:
  - ប័ណ្ណឥណទាន **ប្រ៊ីជ វីសា រីសឺវ** (ទាំងប័ណ្ណបង្គោល និង ប័ណ្ណរង)
  - ប័ណ្ណឥណទាន **ប្រ៊ីជ វីសា ផ្លាទីនៀម** (ទាំងប័ណ្ណបង្គោល និង ប័ណ្ណរង)
  - ប័ណ្ណឥណពន្ធ **ប្រ៊ីជ វីសា ផ្លាទីនៀម**
  - ប័ណ្ណឥណពន្ធ **ស៊ីអេសអេស ប្រ៊ីជ ព្រីមៀរ**។

### ៤.២ លក្ខខណ្ឌនៃការប្រើប្រាស់ និង បទប្បញ្ញត្តិ

- អត្ថប្រយោជន៍នេះគឺសម្រាប់តែម្ចាស់ប័ណ្ណ ប្រ៊ីជ ដែលមានសិទ្ធិទទួលការផ្តល់ជូននេះតែប៉ុណ្ណោះ ដោយ**មិនអាចផ្ទេរ ឬ ផ្តល់សិទ្ធិទៅកាន់បុគ្គលផ្សេងទៀតឡើយ។**
- ការផ្តល់ជូននេះមិនអាចផ្ទេរ ឬ បូកបញ្ចូលគ្នា ឬ ប្តូរជាសាច់ប្រាក់ ឬ ផលិតផលផ្សេងទៀតបានទេ ព្រមទាំងមិនអាចប្រើរួមជាមួយការផ្តល់ជូនផ្សេងៗទៀត ឬ បញ្ចុះតម្លៃទំនិញផ្សេងទៀតបានឡើយ។

### ៤.៣ សម្រាប់សេវាប្រឹក្សាយោបល់អតិថិជន

- ប្រសិនបើលោកអ្នកត្រូវការព័ត៌មានបន្ថែម ត្រូវការជំនួយ ឬជួបប្រទះបញ្ហាណាមួយ សូមទាក់ទងមកកាន់យើងខ្ញុំតាមរយៈ

**លេខទូរសព្ទ:** ១៨០០ ២០២ ៩៩៩/ ០៩៨ ២០២ ៩៩៩
**អ៊ីម៉ែល:** info@bridgebank.com.kh
**ហ្វេសប៊ុក:** BRIDGE Bank

BRIDGE BANK

### ៤.៤ វិសោធនកម្ម

- ធនាគារ ប្រ៊ីដ រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរលក្ខខណ្ឌនានាគ្រប់ពេលវេលា រួមទាំង ការកំណត់ផ្លាស់ប្តូរប្រភេទប័ណ្ណដែលនឹងត្រូវផ្តល់ជូន និង យន្តការគណនា ឬ ធ្វើការបញ្ចប់ការផ្តល់ជូននេះដោយពុំមានការជូនដំណឹងជាមុនដល់ម្ចាស់ប័ណ្ណ។

## ៥. ការពិនិត្យសុខភាពប្រចាំឆ្នាំ

### ៥.១ លក្ខខណ្ឌក្នុងការទទួលបាន

- អត្ថប្រយោជន៍ពិនិត្យសុខភាពប្រចាំឆ្នាំនេះ នឹងត្រូវបានផ្តល់ជូនម្ចាស់ប័ណ្ណ ប្រ៊ីដ ដោយដៃគូ សហការជាមួយរបស់ធនាគារប្រ៊ីដគឺ មជ្ឈមណ្ឌលវេជ្ជសាស្រ្តសិង្ហបុរី នៅកម្ពុជា។ ដែលនឹងត្រូវបានអនុវត្តចំពោះតែម្ចាស់ប័ណ្ណទាំងឡាយណាដែលបានបំពេញតាមលក្ខខណ្ឌរបស់កម្មវិធីតែប៉ុណ្ណោះ រួមមានប្រភេទប័ណ្ណដូចជា៖
    - ប័ណ្ណឥណទាន **ប្រ៊ីដ វីសា វីស៊ីរ** (ទាំងប័ណ្ណបង្គោល និង ប័ណ្ណរង)
    - ប័ណ្ណឥណទាន **ប្រ៊ីដ វីសា ផ្លាទីនៀម** (ទាំងប័ណ្ណបង្គោល និង ប័ណ្ណរង)
    - ប័ណ្ណឥណពន្ធ **ប្រ៊ីដ វីសា ផ្លាទីនៀម**។

### ៥.២ ការផ្តល់ជូនកញ្ចប់ពិនិត្យសុខភាព

- ម្ចាស់ប័ណ្ណឥណទាន **ប្រ៊ីដ វីសា វីស៊ីរ** មានសិទ្ធិទទួលបានការពិនិត្យសុខភាពប្រចាំឆ្នាំក្រោម 'កញ្ចប់ Comprehensive' ពី មជ្ឈមណ្ឌលវេជ្ជសាស្រ្តសិង្ហបុរី នៅកម្ពុជា ដែលផ្តល់ជូនដោយស្វ័យប្រវត្តិ។
- ម្ចាស់ប័ណ្ណឥណទាន និងឥណពន្ធ **ប្រ៊ីដ វីសា ផ្លាទីនៀម** មានសិទ្ធិទទួលបានការពិនិត្យសុខភាពប្រចាំឆ្នាំក្រោម 'កញ្ចប់ Foundation' ពី មជ្ឈមណ្ឌលវេជ្ជសាស្រ្តសិង្ហបុរី នៅកម្ពុជា នៅពេលដែលម្ចាស់ប័ណ្ណ បានចំណាយលើការទូទាត់ប្រចាំឆ្នាំចំនួន ១២,០០០.០០ ដុល្លារអាមេរិក (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក)។

### ៥.៣ លក្ខខណ្ឌនៃការប្រើប្រាស់ និង បទប្បញ្ញត្តិ

- កម្មវិធីនេះមិនអនុវត្តចំពោះបុគ្គលិកធនាគារ ប្រ៊ីដ ដែលកាន់ប័ណ្ណ **ប្រ៊ីដ វីសា ផ្លាទីនៀម** ឡើយ។
- ចំពោះកញ្ចប់ពិនិត្យសុខភាពណាមួយដែលមានតម្លៃលើសពីការផ្តល់ជូនរបស់ធនាគារ ប្រ៊ីដ មជ្ឈមណ្ឌលវេជ្ជសាស្រ្តសិង្ហបុរី រក្សាសិទ្ធិក្នុងការទូទាត់ប្រាក់ពីអតិថិជនដោយផ្ទាល់សម្រាប់សេវាកម្មទាំងនោះ។

- ការពិនិត្យសុខភាពប្រចាំឆ្នាំនេះ ត្រូវតែប្រើប្រាស់ត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៥។ ចំពោះអត្ថប្រយោជន៍ដែលមិនបានប្រើប្រាស់ រហូតដល់ហួសសុពលភាពនឹងត្រូវបាត់បង់សិទ្ធិក្នុងការប្រើប្រាស់ដោយស្វ័យប្រវត្តិ។
- អត្ថប្រយោជន៍នេះគឺសម្រាប់តែម្ចាស់ប័ណ្ណប៉ុណ្ណោះ ហើយមិនអាចផ្តល់ជូនចំពោះអ្នកផ្សេងបានឡើយ។
- ការផ្តល់ជូននេះមិនអាចផ្ទេរ ឬ ប្តូកបញ្ចូលគ្នា ឬ ប្តូរជាសាច់ប្រាក់ ឬ ផលិតផលផ្សេងទៀតបានទេ ឬ ប្រើរួមជាមួយការផ្តល់ជូនផ្សេងៗទៀត ឬ ប្រភេទទំនិញលក់បញ្ចុះតម្លៃ ឬ ប្រភេទទំនិញតម្លៃថេរបានឡើយ (លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ)។

### ៥.៤ សម្រាប់សេវាប្រឹក្សាយោបល់អតិថិជន

- ប្រសិនបើលោកអ្នកត្រូវការព័ត៌មានបន្ថែម ត្រូវការជំនួយ ឬ ជួបប្រទះបញ្ហាណាមួយ សូមទាក់ទងមកកាន់យើងខ្ញុំតាមរយៈ

  **លេខទូរសព្ទ:** ១៨០០ ២០២ ៩៩៩/ ០៩៨ ២០២ ៩៩៩
  **អ៊ីម៉ែល:** info@bridgebank.com.kh
  **ហ្វេសប៊ុក:** BRIDGE Bank.

### ៥.៥ វិសោធនកម្ម

- ធនាគារ ប្រ៊ីដ និង មជ្ឈមណ្ឌលវេជ្ជសាស្រ្តសិង្ហបុរី រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរលក្ខខណ្ឌនានាគ្រប់ពេលវេលារួមទាំង ការកំណត់ផ្លាស់ប្តូរប្រភេទប័ណ្ណដែលនឹងត្រូវផ្តល់ជូន និង យន្តការគណនា ឬ ធ្វើការបញ្ចប់ការផ្តល់ជូននេះដោយពុំមានការជូនដំណឹងជាមុនដល់ម្ចាស់ប័ណ្ណ។